# I - ទីស្តីការគណៈរដ្ឋមន្ត្រី

## ១ - អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ : ៣៤ អនក្រ.បក**

**ស្តីពីការបង្កើតអាជ្ញាធរអភិវឌ្ឍន៍កំពង់ឆ្នាំងទទួលបន្ទុក**

**ការអភិវឌ្ឍន៍ព្រលានយន្តហោះកំពង់ឆ្នាំង**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ១០៩៤–៨៣ នស/រកត ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ១០៩៤–៩០ នស.រកត ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណូមពរការងារចាំបាច់

**សំរេច**

**មាត្រា ១** : បង្កើតអាជ្ញាធរអភិវឌ្ឍន៍កំពង់ឆ្នាំង ទទួលបន្ទុកការអភិវឌ្ឍន៍ព្រលានយន្តហោះកំពង់ឆ្នាំង ដោយក្រុមហ៊ុនចំរុះ រវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយក្រុមហ៊ុន DRAGON GOLD SDN BHD ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម **សុខ អាន** និង ឯកឧត្តម **ម៉េង សារីទុឡា** សហរដ្ឋមន្ត្រី
ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឬ តំណាង ជាសហប្រធាន

២-ឯកឧត្តម **ណា ឌីអាន់** អគ្គលេខាធិការរាជរដ្ឋាភិបាល ឬ តំណាង
ជាលេខាធិការ

៣-ឯកឧត្តម **ប៊ុក សំឯល** រដ្ឋលេខាធិការអាកាសចរស៊ីវិល ឬតំណាង
ជាសមាជិក

៤-ឯកឧត្តម **គ្រាំ អ៊ីវតឹក** រដ្ឋលេខាធិការក្រសួងសាធារណការ និង
ដឹកជញ្ជូន ឬតំណាង ជាសមាជិក

៥-ឯកឧត្តម **ចាយ សាំងយុន** រដ្ឋលេខាធិការក្រសួងការពារជាតិឬតំណាង
ជាសមាជិក

៦-ឯកឧត្តម **ហេង វង្សប៊ុនឆាត** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ឬតំណាង
ជាសមាជិក

៧-ឯកឧត្តម **ស៊ុន ចាន់ថុល** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង
ហិរញ្ញវត្ថុ ឬតំណាង ជាសមាជិក

៨-ឯកឧត្តម **ម៉ម សុផាណា** អនុប្រធានអាជ្ញាធរអភិវឌ្ឍន៍អាកាស
យានដ្ឋាន ឬតំណាង ជាសមាជិក

៩-អ្នកអង្គម្ចាស់ **នរោត្តម ម៉ាត់ ម៉ានី** មេបញ្ជាការទ័ពអាកាសខ្មែរ
ឬតំណាង ជាសមាជិក

១០-តំណាងនៃក្រុមប្រឹក្សានគរោបនីយកម្ម ជាសមាជិក

១១-ឯកឧត្តម **តោក សាម៉ឿន** អភិបាលខេត្តកំពង់ឆ្នាំង និង ឯកឧត្តម
**ឡាវ សួត** អភិបាលរងទី ១ ឬតំណាង
ជាសមាជិក

១២-បណ្ឌិត **ចុង គួង យូអាន** ( Dr. Chong Kwong Yuan ) និង
បណ្ឌិត **យាន គ្រេយ** ( Dr. Iain Gray ) តំណាងរបស់ក្រុម ៊ាន

DRAGONGOLD SDN BHD ឬតំណាង ជាសមាជិក

មាត្រា ២ : អាជ្ញាធរនេះ មានភារកិច្ចទទួលបន្ទុកពិនិត្យសិក្សាលើកិច្ចព្រមព្រៀង និងគ្រប់គំរោង សំរាប់ការអភិវឌ្ឍន៍ព្រលានយន្តហោះកំពង់ឆ្នាំង របស់ក្រុមហ៊ុនវិនិយោគ DRAGONGOLD SDN BHD ដើម្បីជ្រើសរើស និងស្នើជាយោបល់ថ្វាយ និង ជូននាយករដ្ឋមន្ត្រីសំរេច ។ ក្រោយពីមានការសំរេចជាគោលការណ៍ អាជ្ញាធរមានភារកិច្ចរៀបចំពិនិត្យលំអិត និងចុះហត្ថលេខាលើកិច្ចសន្យាជា មួយក្រុមហ៊ុនក្នុងនាមរាជរដ្ឋាភិបាល ។

មាត្រា ៣ : អាជ្ញាធរនេះមានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយដើម្បីជួយការងារ និង មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ និង សម្តេច ឯកឧត្តម អស់លោក ដូចមានឈ្មោះក្នុងមាត្រា១ ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយ ព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ : ១២៥ អនក្រ.តត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា